# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីជូនដំណឹង
## ស្តីពីពិព័រណ៍ការងារ និងផលិតភាពបាត់ដំបង ឆ្នាំ២០១៩
## ថ្ងៃទី០៦-០៧ ខែធ្នូ ឆ្នាំ២០១៩
## នៅបរិវេណវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់មន្ទីរ ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារធ្វើ សិស្ស និស្សិត ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងសាធារណជន មេត្តាជ្រាបថា **ពិព័រណ៍ការងារ និងផលិតភាពបាត់ដំបង ឆ្នាំ២០១៩** នឹងត្រូវបានរៀបចំរយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៩ ពីម៉ោង ០៨:០០ នាទីព្រឹក ដល់ម៉ោង ១៨:០០ នាទីល្ងាច នៅបរិវេណវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង តាមបណ្តោយផ្លូវជាតិលេខ៥ ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។ ពិព័រណ៍ការងារនេះត្រូវបានរៀបចំឡើងក្រោមកិច្ចសហការជិតស្និទ្ធពីសាលាខេត្តបាត់ដំបង សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) ខេត្តបាត់ដំបង ដោយទទួលបានការឧបត្ថម្ភគាំទ្រពីអង្គការ Finn Church Aid (FCA) និងវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង ក្នុងគោលបំណងដើម្បី៖

- បង្កើតជាវេទិកាការងារដ៏ធំនៅមួយកន្លែងដោយងាយស្រួល សម្រាប់និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងអ្នកស្វែងរកការងារធ្វើ ដើម្បីតាំងបង្ហាញ ធ្វើការផ្លាស់ប្តូរ និងចែករំលែកព័ត៌មានទីផ្សារការងារ។
- និយោជកអាចធ្វើការផ្សព្វផ្សាយពីតម្រូវការជ្រើសរើសកម្លាំងពលកម្មនាពេលបច្ចុប្បន្ន និងអនាគត ដើម្បីទាក់ទាញអ្នកស្វែងរកការងារធ្វើដែលមានសមត្ថភាព។
- អ្នកស្វែងរកការងារធ្វើអាចដាក់ពាក្យ និងសម្ភាសការងារនៅនឹងកន្លែងផ្ទាល់ ព្រមទាំងទទួលបានព័ត៌មានអំពីឱកាសការងារនាពេលបច្ចុប្បន្ន និងអនាគត ព្រមទាំងឱកាសក្នុងការអភិវឌ្ឍជំនាញនានា។
- អ្នកផ្តល់ការអប់រំបណ្តុះបណ្តាលអាចផ្សព្វផ្សាយកម្មវិធីសិក្សាវគ្គសិក្សា និងអភិវឌ្ឍជំនាញគ្រប់ប្រភេទ។
- លើកកម្ពស់ការយល់ដឹង និងបណ្តុះគំនិតអំពីផលិតភាពតាមរយៈការបង្ហាញគំនិត បទពិសោធន៍ ជំនាញ បច្ចេកវិទ្យា និងការអនុវត្តល្អសម្រាប់លើកកម្ពស់ផលិតភាព ប្រសិទ្ធភាពក្នុងការងារដោយវាគ្មិនជាតិ-អន្តរជាតិល្បីៗ។
- ផ្តល់ឱកាសក្នុងការរឹតបណ្តឹងបណ្តាញទំនាក់ទំនងផ្នែកធនធានមនុស្សពីគ្រប់វិស័យ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រប់មន្ទីរ ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ អ្នកស្វែងរកការងារធ្វើ និងសាធារណជន ដែលមានបំណងចូលរួមតាំងបង្ហាញស្លាកសញ្ញា ឱកាសការងារ ជ្រើសរើសកម្លាំងពលកម្ម និងស្វែងរកការងារ សូមធ្វើការទាក់ទងសួរព័ត៌មានពិស្តារអំពីព្រឹត្តិការណ៍ពិព័រណ៍ការងារខាងលើនេះតាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខទូរស័ព្ទ ០១៧ ៤៦៧ ៤២៣ ឬចូលមើលគេហទំព័រ **www.event.nea.gov.kh**។

ថ្ងៃ សុក្រ ១២កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ២០១៩